# រកបានប្រាក់បន្ថែមទៀតពីកម្មវិធី SNAP

## ជាមួយនឹងកម្មវិធីរង្វាន់លើកទឹកចិត្តដើម្បីសុខភាពល្អ (Healthy Incentives Program)

**កសិកម្មដែលគាំទ្រដោយសហគមន៍ [Community-Supported Agriculture (CSA)] Farm Shares (ភាគហ៊ុនកសិដ្ឋាន) ផ្តល់ជូនលោកអ្នកនូវសិទ្ធចេញចូលទៅទិញបន្លែនិងផ្លែឈើដែលជួយឲ្យសុខភាពល្អជាប្រចាំសប្តាហ៍ និងគាំទ្រដល់កសិករក្នុងតំបន់ផងដែរ ។ ជាវ Farm Share របស់កសិកម្មគាំទ្រដោយសហគមន៍ (CSA) និងរកបានប្រាក់បន្ថែមសម្រាប់ម្ហូបអាហារ តាមរយៈកម្មវិធីលលើកទឹកចិត្តផ្នែក**

## តើអ្វីទៅជា CSA?

កម្មវិធីកសិកម្មដែលគាំទ្រដោយសហគមន៍ [Community-Supported Agriculture (CSA)] គឺជាភាពដៃគូរវាងកសិករនិងសហគមន៍របស់ពួកគេ ។ សមាជិកទាំងឡាយ ទិញភាគហ៊ុន (share)មួយចំណែកនៃភោគផលកសិកម្មជាមុនមុនពេលរដូវដាំដុះបានមកដល់ ហើយទទួលបាននូវរង្វាន់ឬអំណោយជាបន្លែយ៉ាងក្រាស់ក្រែល (ដែលជួនកាលជាផ្លែឈើ) ដែលធម្មតាគឺក្នុងរវាងចន្លោះខែមិថុនាដល់ខែវិច្ឆិកា ។ ការធ្វើដូចនេះ អនុញ្ញាតឲ្យកសិករទាំងឡាយរៀបចំផែនការដាំដុះរបស់ពួកគាត់បានកាន់តែមានប្រសិទ្ធិភាព ព្រោះថា ពួកគាត់ដឹងថាមានកសិផលចំនួនប៉ុន្មានដែលមនុស្សម្នាត្រូវការ និងមានប្រាក់សម្រាប់បង់ថ្លៃចំណាយពលកម្មនិងចំណាយលើសម្ភារ:ឧបករណ៍នានានៅដើមរដូវ ដែលជាពេលដែលពួកគាត់ត្រូវការវាខ្លាំងបំផុត ។



## តើអ្វីទៅជាភាគហ៊ុនកសិដ្ឋានកសិកម្មដែលគាំទ្រដោយសហគមន៍(CSA Farm Share)នោះ?

CSAs ជាទូទៅ ទាមទារនូវការបង់ថ្លៃពេញជាមុន ប៉ុន្តែមិនជានិច្ចកាលវាអាចធ្វើទៅបានដោយគ្រប់ៗគ្នានោះទេ ។ កម្មវិធី CSA Farm Share អនុញ្ញាតឲ្យអតិថិជនរបស់ SNAP ទទួលបានដោយរីករាយនូវអត្ថប្រយោជន៍(benefits)ដែលជាឪកាសក្នុងការចូលរួមក្នុងកម្មវិធីកសិកម្មគាំទ្រដោយសហគមន៍(CSA) នៅពេលដែលបង់ប្រាក់ចំនួនណាមួយ ជាលក្ខណ:ប្រចាំខែ (ដោយប្រើ SNAP)ជំនួសឲ្យការបង់ចំនួនទាំងអស់ក្នុងពេលតែមួយ ។

**HIP នឹងដាក់ចំនួនឲ្យបានស្មើគ្នា នឹងចំនួននៃការទិញរបស់អ្នកទទួល SNAPដែលទិញភាគហ៊ុនកសិដ្ឋានកសិកម្មគាំទ្រដោយសហគមន៍ (CSA Farm Shares)ពីកសិដ្ឋាននានាដែលចូលរួមមកពីទូទាំងរដ្ឋ Massachusetts ភ្លាមៗនោះ គឺបន្ថែមចំនួននៃការបង់ប្រាក់របស់អ្នកត្រឡប់ចូលទៅក្នុងកាត EBT របស់អ្នកទៅវិញ ។**

**សូមមើលថាតើអ្នកអាចទទួលបានប្រាក់កម្រៃប៉ុន្មានក្នុងមួយខែៗ ! (គឺអាស្រ័យទៅតាមទំហំគ្រួសារ)**

**$40** 1-2 នាក់ | **$60** 3-5 នាក់ | **$80** 6+ នាក់

# ជំហ៊ានរបស់ CSA FARM SHARE ៖



1. ជ្រើសរើសយកកម្មវិធី **CSA Farm Share Program** ដែលមានលក្ខណៈងាយស្រួលបំផុតដល់គ្រួសាររបស់អ្នក (មានជម្រើសនានាជាច្រើនពេញមួយឆ្នាំ និងមានការចុះឈ្មោះជាបន្ត) ។



2. សូមចូលទៅគេហទំព័រ **www.mass.gov/HIP** ដើម្បីស្វែងរកទីតាំងទាំងឡាយដែលនៅជិតអ្នក ។
3. ទាក់ទងកសិដ្ឋានដែលចូលរួមណាមួយ ដើម្បីចុះឈ្មោះចូល និងបំពេញកិច្ចសន្យាចូលជាសមាជិក ។




4. សូមមើលថា ប្រាក់បង់សម្រាប់ **CSA** របស់អ្នក ដាក់ចូលទៅក្នុងគណនី **EBT** របស់អ្នកនៅក្នុងថ្ងៃតែមួយនឹងថ្ងៃដែលលោកអ្នកទទួលអត្ថប្រយោជន៍ **SNAP**របស់លោកអ្នកដែរឬទេ ក្នុងខែនីមួយៗនោះ ។



5. ទទួលបានរង្វាន់លើកទឹកចិត្តពី **HIP** ជាស្វ័យប្រវត្តិ នៅពេលប្រាក់បង់ចំពោះ **CSA** របស់អ្នក ត្រូវបានបញ្ចូលឡើង **(posted)** ។



6. មកយកចំណែកភាគហ៊ុនរបស់អ្នកជារៀងរាល់សប្តាហ៍ ។
7. ប្រើប្រាស់ប្រាក់ដែលអ្នករកបានពីការធ្វើដូចនេះ នៅកន្លែងទទួលប្រាក់ណាដែលគេទទួលយកប្រព័ន្ធ **SNAP** ។

## រកទីតាំងរបស់ HIP (HIP LOCATION) ដែលនៅក្បែរលោកអ្នក ។

សូមចូលទៅកាន់គេហទំព័រ ដែលមានអាសយដ្ឋាន **www.mass.gov/hip** ដើម្បីរកបញ្ជីរាយនាមនិងអាសយដ្ឋានទំនាក់ទំនង ឬក៏ទូរស័ព្ទទៅកាន់ប្រព័ន្ធទំនាក់ទំនងបន្ទាន់របស់ **Project Bread's FoodSource (Hotline)** តាមលេខ **1-800-645-8333** ។

*គាំទ្រដោយ USDA FINI និងសហជនរដ្ឋ Commonwealth of Massachusetts ។*